ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

## សូមគោរពជូន

## សម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានគណបក្សប្រជាជនកម្ពុជា និងជា នាយករដ្ឋមន្ត្រី នៃ ព្រះរាជាណាចក្រកម្ពុជា

**សម្តេចអគ្គមហាសេនាបតីតេជោ** ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត !

ជាបឋម តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ និងក្នុងនាមខ្ញុំនិងភរិយាខ្ញុំ ព្រមទាំងសមាជិក សមាជិកា ក្រុមការងារទាំងអស់ សូមសម្តែងនូវមនោសញ្ចេតនា សោមនស្សរីករាយ ឥតឧបមា និងអបអរសាទរ យ៉ាងក្លៀវក្លាបំផុត ចំពោះ **សម្តេចតេជោ** និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ព្រមទាំង បុត្រា បុត្រី ចៅប្រុស ចៅស្រី ក្នុងឱកាសដ៏មហានក្ខត្តឫក្ស ឧត្តុង្គឧត្តមថ្លៃថ្លាបំផុត ដែលសន្និបាតគណៈកម្មាធិការកណ្តាល លើកទី៣៨អាណត្តិទី៥ គណបក្សប្រជាជនកម្ពុជា បោះឆ្នោតជាឯកច្ឆន្ទជ្រើសតាំង **សម្តេចអគ្គមហាសេនាបតីតេជោ** ជាប្រធានគណបក្ស**ប្រជាជនកម្ពុជា** នាថ្ងៃទី ២០ ខែមិថុនា ឆ្នាំ២០១៥ ។

ការបោះឆ្នោតជ្រើសតាំង **សម្តេចតេជោ** ជាប្រធាន គណបក្សប្រជាជនកម្ពុជា គឺជាសក្ខីភាព ឆ្លុះបញ្ចាំងឲ្យឃើញពីសមត្ថភាព និងភាពជាមេដឹកនាំចាស់ទុំនយោបាយ និងការលះបង់ធ្វើពលិកម្មមិនចេះនឿយហត់របស់ **សម្តេចតេជោ** ដែលបានបូជាកម្លាំងកាយ-ចិត្ត ដើម្បីបុព្វហេតុដ៏ឧត្តុង្គឧត្តម ក្នុងការបំរើប្រទេសជាតិ មាតុភូមិ និងប្រជាពលរដ្ឋ ។

យើងខ្ញុំទាំងអស់គ្នា សូមសម្តែងនូវការគោរពដឹងគុណ ប្រកបដោយភក្តីភាព និងកោតស្ញប់ស្ញែង ចំពោះ **សម្តេចតេជោ** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងជា ប្រធាន គណបក្សប្រជាជនកម្ពុជា ដែលជាឥស្សរជន និងជាវីរជនដ៏ឆ្នើមបំផុត ដែលបានតស៊ូរំដោះប្រទេសជាតិឲ្យរួចផុតពីរបបប្រល័យពូជសាសន៍ ប៉ុល ពត ទប់ស្កាត់បានទាំងស្រុង នូវការប៉ុនប៉ងវិលត្រឡប់មកវិញ នូវរបបប្រល័យពូជសាសន៍ជាថ្មីម្តងទៀតនៅកម្ពុជា ព្រមទាំងបានស្តារនិងអភិវឌ្ឍន៍ប្រទេសឲ្យមានការរីកចម្រើនលើគ្រប់វិស័យ ជាពិសេសឆ្លងកាត់អន្តរកាលជាបន្តបន្ទាប់ រហូតដល់ដំណាក់កាលថ្មីនេះ **សម្តេចតេជោ** គឺជា **រដ្ឋបុរស** ដ៏ឈ្លាសវៃ និងប៉ិនប្រសប់ ក្នុងការបង្រួបបង្រួមជាតិ ផ្សះផ្សាជាតិ ដឹកនាំអនុវត្តដោយជោគជ័យ នូវ នយោបាយ **ឈ្នះ! ឈ្នះ!** សម្រេចបាននូវសន្តិភាពពេញលេញនៅលើទឹកដី នៃព្រះរាជាណាចក្រកម្ពុជា ថែរក្សា ការពាររឹងមាំ បូរណភាពទឹកដី សន្តិសុខ ស្ថិរភាពសង្គម និងអភិវឌ្ឍន៍ប្រទេសជាតិរីកចំរើនឈានឡើងលើគ្រប់វិស័យ កាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ។

យើងខ្ញុំទាំងអស់គ្នា សូមគោរពនិងដើរតាមដាច់ខាត ចំពោះមាគ៌ានយោបាយ និងការដឹកនាំរបស់ **សម្តេច** ជារៀងរហូតនិងចងចាំជានិច្ច ចំពោះគុណូបការៈនិងគុំវីរៈភាពដ៏ល្អប្រសើរ ព្រមទាំងពលិកម្មដ៏ថ្លៃថ្លានិងទឹកចិត្តស្នេហាជាតិ ដ៏ឧត្តុង្គឧត្តមរបស់ **សម្តេចតេជោ** និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ចំពោះជាតិ មាតុភូមិ និងប្រជាជនជាទីស្នេហានៃយើង ។

ក្នុងឱកាសដ៏មហានក្ខត្តឫក្ស ឧត្តុង្គឧត្តម ប្រពៃថ្លៃថ្លានេះ យើងខ្ញុំទាំងអស់គ្នា សូមប្រសិទ្ធិពរសព្ទសាធុការជ័យគ្រប់ប្រការ ជូនចំពោះ **សម្តេចប្រធាន** គណបក្សប្រជាជនកម្ពុជា សូមមាន សុខភាពល្អបរិបូរណ៍ ជន្មាយុយឺនយូរ បញ្ញាញាណ ភ្លឺថ្លា ត្រចះត្រចង់ ដើម្បីបន្តដឹកនាំរាជរដ្ឋាភិបាលកម្ពុជា និងដឹកនាំគណបក្សប្រជាជនកម្ពុជា ប្រកបដោយវឌ្ឍនភាព និងវិបុលភាព តរៀងទៅ ។

សូម **សម្តេចប្រធាន** មេត្តាទទួលនូវការគោរព ដ៏ខ្ពង់ខ្ពស់បំផុតអំពីខ្ញុំបាទ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និងជាសមាជិក**

**គណៈអចិន្ត្រៃយ៍ គណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា**

**ទៀ បាញ់**